**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# ភ្លុកមានជ័យ
# សម្រាប់រយៈពេល ៣ ឆ្នាំ
# ( កក្កដា ២០១៩ - មិថុនា ២០២២ )

| | |
|---|---|
| សហគមន៍នេសាទ | ៖ ភ្លុកមានជ័យ |
| ភូមិ | ៖ ភូមិភ្លុក និងបានប៊ុង |
| ឃុំ | ៖ ភ្លុក |
| ស្រុក | ៖ សេសាន |
| ខេត្ត | ៖ ស្ទឹងត្រែង |

**ខែកុម្ភៈ ឆ្នាំ២០១៩**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# ភ្លុកមានជ័យ
# សម្រាប់រយៈពេល ៣ ឆ្នាំ
# ( កក្កដា ២០១៩ - មិថុនា ២០២២)

| | | |
|---|---|---|
| សហគមន៍នេសាទ | ៖ | ភ្លុកមានជ័យ |
| ភូមិ | ៖ | ភូមិភ្លុក និងបានប៊ុង |
| ឃុំ | ៖ | ភ្លុក |
| ស្រុក | ៖ | សេសាន |
| ខេត្ត | ៖ | ស្ទឹងត្រែង |

ខែកុម្ភៈ ឆ្នាំ២០១៩

# មាតិកា


១. ស្ថានភាពទូទៅ.......................................................................................................៣
២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម.......................................................................៤
ក. ប្រជាពលរដ្ឋ.........................................................................................................៤
ខ. មុខរបរ ..................................................................................................................៤
៣. កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទ ............................៥
ក. ទីតាំង ....................................................................................................................៥
ខ. ដែននេសាទ...........................................................................................................៥
គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអន្លង់អភិរក្ស និងទីជម្រក..............................៧
ឃ. ធនធានជលផល.....................................................................................................៧
៤. ការធ្វើនេសាទ........................................................................................................៨
ក. អ្នកនេសាទ ............................................................................................................៨
ខ. ឧបករណ៍នេសាទ.....................................................................................................៨
៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ...................................................................៩
ក.ទស្សនៈវិស័យ .........................................................................................................៩
ខ. គោលបំណងរួម .......................................................................................................៩
គ. គោលបំណងជាក់លាក់ ..............................................................................................៩
ឃ. ផែនការសកម្មភាពគ្រប់គ្រងកន្លែងនេសាទសហគមន៍ ...................................................១០
ឃ.១. ធនធានជលផល និងអេកូឡូស៊ី...........................................................................១០
ឃ.២. ការគាំទ្រជីវភាពប្រជាពលរដ្ឋ.............................................................................១២
ឃ.៣. ការគ្រប់គ្រង.....................................................................................................១៤
ង. ផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ...............................................................១៧
ផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃត្រូវបានរៀបចំខាងក្រោមៈ .............................១៧
ច. យុទ្ធសាស្ត្រ.............................................................................................................១៧
តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍រយៈពេល ៣ ឆ្នាំ (កក្កដា ២០១៩- មិថុនា ២០២២).........១៩
តារាងកម្មវិធីការងារប្រចាំឆ្នាំ (ខែកក្កដា ២០១៩ -មិថុនា ២០២២)..............................................២៤

# ផែនការគ្រប់គ្រង
# តំបន់នេសាទសហគមន៍

## ១. ស្ថានភាពទូទៅ

សហគមន៍នេសាទភ្លុកមានជ័យ បានបង្កើតឡើងដោយមហាសន្និបាតកំណើតដំបូងនៅទី១២ ខែកុម្ភៈ ឆ្នាំ២០០៩ ហើយបានចុះកិច្ចព្រមព្រៀងតំបន់នេសាទសហគមន៍លើកទី១ រយៈពេល៣ឆ្នាំ គឺចាប់ពីថ្ងៃទី១៥ ខែមិនា ឆ្នាំ២០១១ ដល់ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៣ និងបានចុះកិច្ចព្រមព្រៀងតំបន់នេសាទសហគមន៍លើកទី២ រយៈពេល៣ឆ្នាំ ចាប់ពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ដល់ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៩ និងបានចុះកិច្ចព្រមព្រៀងលើកទី៣ ចាប់ពីថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៩ ដល់ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២១។ សហគមន៍នេសាទមានទីតាំងស្ថិតនៅក្នុងភូមិភ្លុក និងភូមិបានប៊ុង ឃុំភ្លុក ស្រុកសេសាន ខេត្តស្ទឹងត្រែង ដែលមានសមាជិកសហគមន៍នេសាទសរុបចំនួន២៩៣នាក់ ស្រីចំនួន១៥៤នាក់ ស្មើនឹង១១២គ្រួសារ និងមានគណៈកម្មការចំនួន៧នាក់ ស្រីចំនួន០២នាក់។ សហគមន៍នេសាទភ្លុកមានជ័យ ត្រូវបានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រកាសទទួលស្គាល់នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១។

បន្ទាប់ពីបានបោះឆ្នោតជ្រើសរើសគណៈកម្មការរួចមក សហគមន៍នេសាទបានអនុវត្តសកម្មភាពសំខាន់ៗដូចជា ការរៀបចំបញ្ជីឈ្មោះ និងរចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍នេសាទ បច្ចុប្បន្នភាពសមាជិក លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ចូលរួមកំណត់ព្រំប្រទល់តំបន់នេសាទសហគមន៍ រៀបចំកិច្ចព្រមព្រៀងតំបន់នេសាទ ការរៀបចំក្រុមល្បាត និងចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា ។ បន្ថែមពីនេះទៀត បានចុះល្បាតជាប្រចាំក្នុងការទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផល ដែលកើតមាននៅក្នុងតំបន់នេសាទសហគមន៍ ដោយសហការជាមួយសមត្ថកិច្ចជលផល បរិស្ថាន អង្គភាពពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន។ រហូតមកដល់បច្ចុប្បន្នសហគមន៍នេសាទដំណើរការរីកចម្រើន ដោយទទួលបានភាពជោគជ័យក្នុងការកាត់បន្ថយការកាប់បំផ្លាញព្រៃលិចទឹក និងបានកាត់បន្ថយសកម្មភាពបទល្មើសនេសាទនានា ដែលធ្វើឱ្យផលនេសាទមានភាពប្រសើរឡើង។

ទន្ទឹមនឹងសមិទ្ធផលដែលសម្រេចបានដូចខាងលើ សហគមន៍នេសាទនេះ នៅជួបប្រទះបញ្ហាប្រឈមពាក់ព័ន្ធនឹងធនធានជលផលនិងអេកូឡូស៊ី ជីវភាពប្រជាពលរដ្ឋ និងការគ្រប់គ្រង៖

-បញ្ហាប្រឈមពាក់ព័ន្ធនឹងធនធានជលផលនិងអេកូឡូស៊ី រួមមាន ផលប៉ះពាល់អវិជ្ជមានពីទំនប់វ៉ារីអគ្គិសនីសេសាន ២ ធ្វើឱ្យមានបញ្ហាដល់មច្ឆជាតិ ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ច្រើន ដូចជាមងក្រឡាធំ អួន ដាយ ឆក់ បំពុល បោកគ្រាប់បែក មិនតែប៉ុណ្ណោះមានការលួចដាក់មង សន្ទូចនៅតំបន់អភិរក្ស និងអ្នកខាងក្រៅចូលមកនេសាទច្រើនដោយប្រើប្រាស់ឧបករណ៍ខុសច្បាប់

-បញ្ហាប្រឈមពាក់ព័ន្ធនឹងជីវភាពប្រជាពលរដ្ឋ រួមមាន ខ្វះដើមទុនពង្រីកមុខរបរ ខ្វះបច្ចេកទេសដាំដុះ ខ្វះមុខរបរចិញ្ចឹមជីវិត ខ្វះទឹកស្អាតប្រើប្រាស់ និងខ្វះបង្គន់អនាម័យ ព្រមទាំងមិនសូវមានការចូលរួមពីប្រជាពលរដ្ឋ។

-បញ្ហាប្រឈមពាក់ព័ន្ធនឹងការគ្រប់គ្រង រួមមាន ខ្វះថវិកានិងកម្លាំងចុះបង្ក្រាបបទល្មើស ខ្វះទូកនិងសម្ភារចុះល្បាត លំបាកពេលចុះល្បាតពេលយប់ ពេលមានបទល្មើសកើតឡើងមិនដឹងរាយការណ៍ទៅខាងណា អ្នកខាងក្រៅចូលនេសាទច្រើន ការអនុវត្តច្បាប់មិនសូវមានប្រសិទ្ធភាព ខ្វះការយល់ដឹងពីច្បាប់ ខ្វះព័ត៌មានផ្សេងៗទាក់ទងនឹងសហគមន៍-បទល្មើស

នេសាទកើនឡើង សហគមន៍នៅតែគិតថាការងារគណៈកម្មការជាការងារបច្ចេកទេស និងជាតួនាទីរបស់បុរស ចំណែកស្ត្រីមានតួនាទីជាអ្នកថែទាំគ្រួសារការងារផ្ទះ និងលក់ដូរ ចំពោះការចូលរួមរបស់ស្ត្រីក្នុងកិច្ចប្រជុំនានាមានចំនួនច្រើន តែការសម្រេចចិត្តនៅមានកម្រិត។

## ២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក. ប្រជាពលរដ្ឋ

ចំនួនប្រជាពលរដ្ឋក្នុងតំបន់សហគមន៍សរុប១៩៣០នាក់ ស្ត្រី៨១៦នាក់។ ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធមាន១០០%។

ប្រជាពលរដ្ឋក្នុងភូមិត្លុកមានជ័យ មានស្ថានភាពដូចខាងក្រោម៖

- ចំនួនស្ត្រីជាមេគ្រួសារមាន២៥ នាក់
- ចំនួនស្ត្រីមេម៉ាយមាន២៥ នាក់
- ចំនួនបុរសពោះម៉ាយមាន០៥ នាក់
- ចំនួនជនពិការមានប្រុស៨ នាក់(ស្រី០៣ នាក់)
- ចំនួនកុមារកំព្រា០៩ នាក់(ស្រី០៤ នាក់)
- ចំនួនចាស់ជរាមាន១៨ នាក់ (ស្រី១១ នាក់)
- ចំនួនអ្នកមានជម្ងឺរាំរ៉ៃមាន០៦ នាក់ (ស្រី០៣ នាក់)
- កម្រិតសិក្សាអប់រំរួមមានអ្នកមិនចេះអក្សរមានចំនួន១០៧នាក់ ស្រី៥៤នាក់ បឋមសិក្សាចំនួនសរុប៤០នាក់ ស្រី១៨នាក់ វិទ្យាល័យចំនួនសរុប១៥នាក់ ស្រី០៨នាក់ និងវិទ្យាល័យចំនួនសរុប០៨ នាក់ ស្រី០៥នាក់។

### ខ. មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងតំបន់សហគមន៍នេះរួមមាន៖

- អ្នកដែលមានមុខរបរនេសាទជាលក្ខណៈគ្រួសារចំនួន៧២ គ្រួសារ
- ធ្វើស្រែចំនួន១៤៥ គ្រួសារ ដែលមានទំហំដីចំនួន៨០ ហិកតា
- ដាំបន្លែជាលក្ខណៈគ្រួសារចំនួន១៩គ្រួសារ (សួនច្បារជាលក្ខណៈគ្រួសារដែលមានទំហំ៥X១០ ម៉ែត្រ)
- ជាងផ្ទះមានចំនួន០៥គ្រួសារ
- ធ្វើចំការចំនួន៥០ គ្រួសារ ទំហំដីចំការ ១២០ហិកតា
- លក់ដូរជាអាជីព១១ គ្រួសារ (ប៉ាប៊ីង៥គ្រួសារ)
- ប្រមូលទិញផលនេសាទ០៣ គ្រួសារ
- ចិញ្ចឹមសត្វលក្ខណៈគ្រួសារ១០០ % នៃចំនួនគ្រួសារក្នុងភូមិ
- កែច្នៃផលនេសាទជាលក្ខណៈគ្រួសារចំនួនសរុប៨០%គ្រួសាររួមមានផ្អក ប្រហុក ត្រីប្រៃជាដើម ក្នុងមួយគ្រួសារអាចផលិតបានពី២០គីឡូក្រាម ទៅ៥០គីឡូក្រាមក្នុង១ឆ្នាំ

- ជាងកាត់ដេរ០៣ គ្រួសារ
- ស៊ីឈ្នួលប្រមាណ១០០ នាក់
- ពេទ្យសត្វ០៤ នាក់
- មន្ត្រីរាជការ២៥នាក់ (ស្រី១០នាក់)
- ជាងជួសជុលម៉ូតូ០២ នាក់
- ចំណាកស្រុកទៅប្រទេសក្រៅ (ថៃ១០នាក់ និងប្រទេសម៉ាឡេស៊ី០១នាក់)

## ៣. កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទ

ក. ទីតាំង

កន្លែងនេសាទសហគមន៍ភ្លុកមានជ័យជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ។ កន្លែងនេសាទសហគមន៍ភ្លុកមានជ័យមានទំហំ ១០១៨ ហិកតា និងមានកំណត់និយាមការដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

<u>មានព្រំប្រទល់</u>

- ខាងជើងទល់នឹងឃុំស្តៅ ស្រុកសេសាន ខេត្តស្ទឹងត្រែង
- ខាងត្បូងទល់នឹង ក្បាលរមាស ឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង
- ខាងកើតទល់នឹង ស្រែគរ ស្រុកសេសាន ស្រុកសេសាន ខេត្តស្ទឹងត្រែង
- ខាងលិចទល់នឹង ឃុំកំភុន ស្រុកសេសាន ខេត្តស្ទឹងត្រែង។

ខ. ដែននេសាទ

កន្លែងនេសាទសហគមន៍ភ្លុកមានជ័យ មានវិសាលភាពនៅក្នុងទន្លេសេសាន មានអូរចំនួន០៧អូរ ត្រពាំងចំនួន ១៨ត្រពាំង និងអន្លង់ចំនួន១១អន្លង់ រួមមានដូចខាងក្រោម៖

ខ.១. អូរ

| ឈ្មោះអូរ | ប្រវែង (គីឡូម៉ែត្រ) | រដូវនេសាទ |
|---|---|---|
| អូរខ្សាច់ភូមិ | ១៥ | ពេញមួយឆ្នាំ |
| អូរព្រើត | ០៥ | មិថុនា - តុលា |
| អូរកាយ៉ា | ១០ | មិថុនា - តុលា |
| អូរកាយ៉ែង | ១០ | មិថុនា - តុលា |
| អូរកាប៉ុក | ៧ | មិថុនា - តុលា |
| អូរកាអាំ | ១០ | ពេញមួយឆ្នាំ |
| អូរបេង | ១០ គីឡូម៉ែត្រ | ខែ៦ ដល់ខែ១០ |

ខ.២.ត្រពាំង

| ឈ្មោះត្រពាំង | ទំហំសរុប (ម៉ែត្រការេ) | រដូវនេសាទ |
|---|---|---|
| ត្រពាំងធំ | ១០០ x ១០០ | ពេញមួយឆ្នាំ |
| ត្រពាំងខ្ចីម | ៥០ x ៥០ | កក្កដា - វិច្ឆិកា |

| | | |
|---|---|---|
| ត្រពាំងស្តៅ | ៥០ x ៥០ | កក្កដា - វិច្ឆិកា |
| ត្រពាំងតាយ៉ុក | ៨០ x ៥០ | ពេញមួយឆ្នាំ |
| ត្រពាំងក្រាច | ៤០ x ៥០ | ពេញមួយឆ្នាំ |
| ត្រពាំងលាងសាំហាក | ៣០ x ៤០ | ពេញមួយឆ្នាំ |
| ត្រពាំងកូន | ៣០ x ៥០ | ពេញមួយឆ្នាំ |
| ត្រពាំងផ្តៅ | ២០ x ៣០ | ពេញមួយឆ្នាំ |
| ត្រពាំងស្នែងក្របី | ១០០ x ១០០ | ពេញមួយឆ្នាំ |
| ត្រពាំងតាហុង | ១០០ x ៥០ | ពេញមួយឆ្នាំ |
| ត្រពាំងតាតួយ | ៥០ x ៥០ | ពេញមួយឆ្នាំ |
| ត្រពាំងពងទឹក | ២០ x ២០ | ពេញមួយឆ្នាំ |
| ត្រពាំងខ្វង | ៣០ x ២០ | ពេញមួយឆ្នាំ |
| ត្រពាំងក្តុល | ១៥ x ១៥ | ពេញមួយឆ្នាំ |
| ត្រពាំងកួត | ៥០ x ៦០ | ពេញមួយឆ្នាំ |
| ត្រពាំងស្តៅ | ២០ x ៣០ | ពេញមួយឆ្នាំ |
| ត្រពាំងណាងស្មោ | ៤០ x ៥០ | ពេញមួយឆ្នាំ |
| ត្រពាំងលាងតៅង៉ាប់ | ៤០ x ៤០ | ពេញមួយឆ្នាំ |

ខ.៣.អន្លង់

| ឈ្មោះអន្លង់ | ទំហំសរុប (ម៉ែត្រការេ) | រដូវនេសាទ |
|---|---|---|
| អន្លង់វើនសាជីក | ១៥០ x ៥០ | ពេញមួយឆ្នាំ |
| អន្លង់ថ្មពុះ | ២០០ x ១៥០ | ពេញមួយឆ្នាំ |
| អន្លង់ថ្មពពៃ | ២០ x ៥០ | ពេញមួយឆ្នាំ |
| អន្លង់ក្រោលសេះ | ៤០ x ៤០ | ពេញមួយឆ្នាំ |
| អន្លង់វើនមួង | ២០ x ៣០ | ពេញមួយឆ្នាំ |
| អន្លង់មាត់អូរព្រើត | ២០ x ២០ | ពេញមួយឆ្នាំ |
| អន្លង់មាត់អូរខ្សា | ១០ x ១៥ | ពេញមួយឆ្នាំ |
| អន្លង់វើនម៉ាន់ | ១០០ x ១០០ | ពេញមួយឆ្នាំ |
| អន្លង់ក្បាលកោះព្រើត | ៣០០ x ៥០០០ | ពេញមួយឆ្នាំ |
| អន្លង់មាត់អូរទោន | ៣០០ x ៥០០០ | ពេញមួយឆ្នាំ |
| អន្លង់ថ្មក្រហម | ៥០ x ៥០ | ពេញមួយឆ្នាំ |

គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអន្លង់អភិរក្ស និងទីជម្រក

តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្សចំនួន៤ គឺអន្លង់វើនសាដឹក អន្លង់ថ្មពពៃ អន្លង់ថ្មពុះ និងអន្លង់វើនម៉ាន់ តាមការសម្រេចរបស់មហាសន្និបាតសហគមន៍នេសាទភ្លុកមានជ័យ ។

| ឈ្មោះអន្លង់ | ទំហំសរុប (ម៉ែត្រការេ) | ដូវនេសាទ |
|---|---|---|
| អន្លង់វើនសាដឹក | ១៥០ x ៥០ | ពេញមួយឆ្នាំ |
| អន្លង់ថ្មពពៃ | ២០ x ៥០ | ពេញមួយឆ្នាំ |
| អន្លង់ថ្មពុះ | ២០០ x ១៥០ | ពេញមួយឆ្នាំ |
| អន្លង់វើនម៉ាន់ | ១០០ x ១០០ | ពេញមួយឆ្នាំ |

កន្លែងនេសាទសហគមន៍ភ្លុកមានជ័យមានព្រៃលិចទឹកសរុបទំហំ៧ហិកតា ក្នុងនោះមានប្រភេទព្រៃដើមរាំង ដើមរៃទំហំ១ហិកតា និងព្រៃលិចទឹកចម្រុះទំហំ៦ហិកតា នៅក្នុងកន្លែងនេសាទសហគមន៍កោះឃ្លើយ។

ឃ. ធនធានជលផល

១. ប្រភេទត្រី

ត្រីផ្ទក់ ត្រីខ្យា ត្រីត្រសក់ ត្រីឆ្តោ ត្រីប្រាកណ្តុរ ត្រីក្លាំងហាយ ត្រីសណ្តាយ ត្រីក្រាយ ត្រីក្អែក ត្រីកេះ ត្រីឈ្វៀត ត្រីឆ្ពិន ត្រីក្របី ត្រីពោ ត្រីខ្មាន់ ត្រីរៀល ត្រីអាច់កុក ត្រីគ្រុំ ត្រីកន្ធ្រប់ ត្រីស្លឹកឫស្សី ត្រីសង្វាមូល ត្រីល្ពុង ត្រីកន្ធាយ ត្រីបបែល ត្រីឆ្តោក ត្រីឆ្កែង ត្រីព្រួល ត្រីកែ ត្រីកញ្ចុះ ត្រីចេកទុំ ត្រីកញ្ចុះរៃជ្រ ត្រីខ្ចឹង ត្រីផ្ទោង ត្រីឈ្លូញ ត្រីតាអោន ត្រីផ្កាត ត្រីលលក ត្រីប្រណាត ត្រីល្ហូ ត្រីល្មិច ត្រីព្រលូ ត្រីគ្មុល ត្រីកាហែ ត្រីឫសចេក ត្រីលេញ ត្រីខ្លា ត្រីអណ្តាតឆ្កែ ត្រីឆ្តោកកា ត្រីផ្លែផ្តៅ ត្រីថ្ម ត្រីកន្ត្រងប្រេង ត្រីស្លាត និងត្រីដំរី។

២. ប្រភេទវារីសត្វ

កង្កែប អណ្តើក កន្ធាយ ពស់ ហ៊ីង និងគីង្គក់។ (ក្រោយពីសាងសង់ទំនប់វ៉ារីអគ្គិសនីប្រភេទវារីសត្វទាំងនេះស្ទើរតែដាច់ពូជដូចជាៈ ក្តាម ខ្យង ខ្ចៅ គ្រំ លៀស និងកំពិស)

៣. ប្រភេទបក្សី

កុកស កុកក្រក់ មាន់ទឹក មាន់ ប្រវឹក ទាព្រៃ ក្រសារ ក្អែកទឹក និងក្អែកគោក។

៤. ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ

ដើមត្រែង ផ្កាអណ្តែង ដើមរាំងទឹក ដើមត្រស់ ដើមល្ងៀង ដើមថ្លើមអណ្តើក ផ្តៅទឹក វល្លិ៍តាអើក វល្លិ៍ដូងព្រះ កំផ្លោក កំពីញពួយ ចក ស្មោរ ត្រកួន កញ្ឆែត ព្រលិត និងរំចង់ជាដើម។

## ៤. ការធ្វើនេសាទ

ក. អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន១១២គ្រួសារ ស្រី១៥៤នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទក្នុងសហគមន៍មានចំនួន៥០ គ្រួសារ
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន៥៤ គ្រួសារ។

## ខ. ឧបករណ៍នេសាទ

ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ៖

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួន | | | ទំហំ ប្រវែង | | | រដូវប្រើប្រាស់ ឧបករណ៍ នេសាទ |
|---|---|---|---|---|---|---|---|---|
| | | សមាជិក | មិនមែន សមាជិក | អ្នកខាងក្រៅ ភូមិ | សមាជិក | មិនមែន សមាជិក | អ្នកខាង ក្រៅភូមិ | |
| សន្ទូច | ផ្លែ | ១៥០ គ្រួសារ x ១០០ផ្លែ | ១៥គ្រួសារ x៥០ផ្លែ/ គ្រួសារ | ៥គ្រួសារ x ១០០ផ្លែ/ គ្រួសារ | ផ្លែលេខ ១២-១៤ | ផ្លែលេខ ១២-១៤ | ផ្លែលេខ ១២-១៤ | ពេញមួយឆ្នាំ |
| លប | គ្រឿង | ០៥គ្រួសារ x០១គ្រឿង =០៥គ្រឿង | ២គ្រួសារ x០២ គ្រឿង/ គ្រួសារ | 0 | មុខកាត់ ១ ស.ម បណ្តោយ ២ម | មុខកាត់ ១ ស.ម បណ្តោយ ២ម | 0 | មិថុនា-ធ្នូ |
| សំណាញ់ | វង់ | ៣០គ្រួសារ x២ =៦០វង់ | ១០គ្រួសារ x០១វង់/ គ្រួសារ | 0 | សំរុង ៣,៥០ - ៥,៥០ម | សំរុង ៣,៥០ - ៥,៥០ម | 0 | ពេញមួយឆ្នាំ |
| ចាន់ | គ្រឿង | ១២គ្រួសារ x២ =២៤ គ្រឿង | ៣គ្រួសារ x ៣គ្រឿង/ គ្រួសារ | 0 | ទំហំ០,៥ម ប្រវែង១ម | ទំហំ០,៥ម ប្រវែង ១ម | 0 | មិថុនា-ធ្នូ |
| តុំ | គ្រឿង | ៧គ្រួសារx ៣ គ្រឿង= ២១គ្រឿង | ៣គ្រួសារ x ៤គ្រឿង/ គ្រួសារ | 0 | មុខកាត់៣០ ស.ម | មុខកាត់៣០ ស.ម | 0 | ពេញមួយឆ្នាំ |
| មង | ម៉ែត្រ | ១២០ គ្រួសារ x ២០០ម/ គ្រួសារ | ២០គ្រួសារ x ២០០ម/ គ្រួសារ | ៣០គ្រួសារ x ២០០ម/ គ្រួសារ | ប្រវែង៥០ - ១៥០ ម | ប្រវែង៥០- ១៥០ម | ប្រវែង៥០- ដល់១៥០ ម | ពេញមួយឆ្នាំ |

ប្រភេទទូកកាណូត

| ប្រភេទ ទូកកាណូត | ចំនួន (ទូក) | | | ចំណុះ (តោន) | | | កម្លាំងសេះ | | |
|---|---|---|---|---|---|---|---|---|---|
| | សមាជិក | មិនមែន សមាជិក | អ្នកខាង ក្រៅភូមិ | សមាជិក | មិនមែន សមាជិក | អ្នកខាង ក្រៅភូមិ | សមាជិក | មិនមែន សមាជិក | អ្នកខាង ក្រៅភូមិ |
| ទូកអេវជាប់ ម៉ាស៊ីន | ១២០ | ០២ | ០៥ | ៣-៤ | ៣-៤ | ៥-៧ | ៦-១៨ | ៦-១៨ | ១៣- ២០ |
| ទូកអុំ និងចែវ | ០២ | 0 | 0 | ១-២ | 0 | 0 | 0 | 0 | 0 |

គ. ការប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមក្នុង១គ្រួសារ | | |
|---|---|---|---|
| | រដូវប្រាំង (គីឡូក្រាម) | រដូវវស្សា (គីឡូក្រាម) | សរុបប្រចាំឆ្នាំ (គីឡូក្រាម) |
| ត្រី | ៧៤១.១៤ | ៩១៩.៩១ | ១,៦៦១.០៥ |

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ក.ទស្សនៈវិស័យ

សហគមន៍នេសាទឃុំភ្លុកមានជ័យមានទស្សនវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌និងចីរភាពធ្វើឲ្យស្ថានភាពប្រជាពលរដ្ឋប្រសើរឡើងដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

ខ. គោលបំណងរួម

ដើម្បីសម្រេចបាននូវទស្សនវិស័យខាងលើ សហគមន៍នេសាទ មានគោលបំណងរួមដូចខាងក្រោម៖

- ឲ្យស្ថានភាពប្រជាពលរដ្ឋប្រសើរឡើងរួមចំណែកកាត់បន្ថយភាពក្រីក្រ
- ធ្វើឲ្យមច្ឆជាតិកើនឡើង ទប់ស្កាត់បទល្មើសខុសច្បាប់
- ពង្រឹងការគ្រប់គ្រង ដើម្បីធ្វើឲ្យបទល្មើសនេសាទខុសច្បាប់ថយចុះ

គ. គោលបំណងជាក់លាក់

- ផ្សព្វផ្សាយច្បាប់ផ្សេងៗស្តីពីជលផល កាត់បន្ថយការនេសាទខុសច្បាប់
- បង្កើនការផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុទ្ធនានា និងកំណត់តំបន់អភិរក្ស
- បង្កើនសមត្ថភាពគណៈកម្មការ និងសមាជិកសហគមន៍នេសាទឃុំភ្លុក(ភូមិបានប៊ុង និងភូមិភ្លុក)
- ផ្តល់សម្ភារៈនិងមធ្យោបាយល្បាត
- បង្កើនមុខរបរដល់ប្រជាពលរដ្ឋ ផ្តល់ទុន ជំនាញបច្ចេកទេស និងចំណេះដឹងផ្នែកកសិកម្ម

ឃ. ផែនការសកម្មភាពគ្រប់គ្រងកន្លែងនេសាទសហគមន៍

ឃ.១. ធនធានជលផល និងអេកូឡូស៊ី

ឃ.១.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺគិតគូរអំពីប្រភេទ ដែននេសាទ ប្រភេទ ទំហំ ប្រវែងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ ត្រូវបានរៀបចំខាងក្រោម៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| ១.ក្នុងទន្លេ | នេសាទពេញមួយឆ្នាំ ជាលក្ខណៈ គ្រួសារ | ចាន់ | មុខកាត់ ០,៥ ម ប្រវែង ១ ម | ២គ្រឿង /គ្រួសារ | |
| | | លប | មុខកាត់០ ,៥ម ប្រវែង១,៥ ម | ២គ្រឿង/គ្រួសារ | |
| | | សំណាញ់ | ក្រឡា ២,៥ - ៨ ស.ម សម្រុង ៣ - ៥ ម៉ែត្រ | ២វង់/គ្រួសារ | |
| | | សន្ទូចរនង | លេខ១២ - ០៥ | ១០០ផ្លែ/គ្រួសារ | |

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| | | សន្ទូចបង្កៃ | លេខ ១២ - ០៥ | ៥០ផ្លែ/គ្រួសារ | |
| ២.អូរ | ខែ០៦-ខែ១០ | មង | ជម្រៅ ៣ ម ក្រឡា៤-៥ ស.ម | ២០០ម/គ្រួសារ | |
| | | សំណាញ់ | ជម្រៅ ៣ - ៤ម ក្រឡា២,៥ ស.ម | ១វង់/គ្រួសារ | |
| | | សន្ទូចរនង | លេខ១២ - ០៥ | ១៥០ផ្លែ/គ្រួសារ | |
| | | សន្ទូចបង្កៃ | លេខ១២ - ០៥ | ១០០ផ្លែ/គ្រួសារ | |
| | | លប | មុខកាត់០,៨ម ប្រវែង១,៥០ម | ៣គ្រឿង/គ្រួសារ | |
| | | ទ្រូ | មុខកាត់ ៤០ស.ម ប្រវែង១ម | ៥ទ្រូ/គ្រួសារ | |
| | | តុំ | មុខកាត់ ៣០ស.ម | ៣គ្រឿង/គ្រួសារ | |
| ៣.ត្រពាំង | ពេញមួយឆ្នាំ | មង | ជម្រៅ ៣ ម ៤-០៥ស.ម | ២០០ម/គ្រួសារ | |
| | | សំណាញ់ | ១វង់/ជម្រៅ ៣ម ក្រឡា០២ស.ម | ១វង់/គ្រួសារ | |
| | | សន្ទូចបង្កៃ | លេខ១២-០៥ | ៥០ផ្លែ/គ្រួសារ | |
| | | តុំ | មុខកាត់៣០ស.ម | ៣គ្រឿង/គ្រួសារ | |

**ឃ.១.២. ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូដែនទីសហគមន៍នេសាទ**

ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូដែនទីសហគមន៍នេសាទ ត្រូវបានរៀបចំខាងក្រោម៖

| ឈ្មោះដែននេសាទ | ទំហំ/ចំនួន | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ (ដុល្លារ) | អ្នកទទួលខុសត្រូវ | ពេលវេលា | |
|---|---|---|---|---|---|---|
| | | | | | ចាប់ផ្ដើម | បញ្ចប់ |
| កន្លែងនេសាទសហគមន៍ត្លុកមានជ័យ | បង្គោលព្រំធ្វើពីស៊ីម៉ងចំនួន៨ បង្គោល | -រៀបចំក្រុមបោះបង្គោល<br>-ទិញបង្គោលនិងយុទ្ធនាការចុះបោះបង្គោល<br>-ផ្សព្វផ្សាយជាសាធារណៈ (ស្ត្រីជាគណៈកម្មការស.ន ចូលរួមផ្សព្វផ្សាយ) | ៤.០០០ | -គណៈកម្មការ<br>-សមាជិកស.ន<br>-មេភូមិ មេឃុំ | ៧/២០១៩ | ៦/២០២២ |
| | ផ្ទាំងប៉ាណូដែនទីស/ហ នេសាទចំនួន ៣ផ្ទាំង ទំហំ ២ម x ៣ម | ផលិតនិងបោះផ្ទាំងប៉ាណូដែនទី | ១.០០០ | | ៧/២០១៩ | ៦/២០២២ |

**ឃ.១.៣. ផែនការគ្រប់គ្រងព្រៃលិចទឹក**

ផែនការគ្រប់គ្រងព្រៃលិចទឹក ត្រូវបានរៀបចំខាងក្រោម៖

| ឈ្មោះ/ទីតាំង | ទំហំ (ហិកតា) | ប្រភេទកូនឈើដែលត្រូវការពារ | សកម្មភាព | ថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|---|
| អន្លង់ថ្មពុះ | ៥ | ព្រៃលិចទឹកដែលត្រូវធ្វើការការពារនូវប្រភេទព្រៃចម្រុះ សត្វទឹកគ្រប់ប្រភេទ និងត្រីគ្រប់ប្រភេទ | - កំណត់ព្រំប្រទល់កន្លែងអភិរក្ស (ឱ្យស្ត្រី និងបុរសជាគណៈកម្មាការសហគមន៍នេសាទចូលរួមសម្រេចចិត្តក្នុងការកំណត់ទីតាំងបោះបង្គោលព្រំប្រទល់)<br>- ដាក់ស្លាកសញ្ញាហាមកាប់ព្រៃលិចទឹក៤ស្លាកសញ្ញាទំហំ១មx ១ម<br>- ដាក់ស្លាកសញ្ញាតូចៗចំនួន ២០ស្លាកនៅតាមដងអូរនានា<br>- បោះបង្គោលដាក់ស្លាកសញ្ញាដែនទីអភិរក្ស<br>- ផ្សព្វផ្សាយពីសារៈប្រយោជន៍កន្លែងអភិរក្ស<br>- ពង្រឹង និងរៀបចំក្រុមល្បាតជាប្រចាំ | ៣០០ | ៧/២០១៩ | ៦/២០២២ |
| អន្លង់រឿនសាដឹក | ២.៥ | | | ៣០០ | | |

ឃ.២. ការគាំទ្រជីវភាពប្រជាពលរដ្ឋ

ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល

ផែនការមុខរបរបង្កើនប្រាក់ចំណូល ត្រូវបានរៀបចំខាងក្រោម៖

| ប្រភេទមុខរបរ | សកម្មភាព | ប្រភេទពូជ | ថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំប្រមូលផល |
|---|---|---|---|---|---|
| ដាំបន្លែតាមគ្រួសារ ២០គ្រួសារ | -ជ្រើសរើសគ្រួសារស្ម័គ្រចិត្ត<br>-វគ្គបណ្តុះបណ្តាលបច្ចេកទេសដាំបន្លែ និងអនុវត្តផ្ទាល់<br>-ផ្តល់គ្រាប់ពូជបន្លែ<br>- ត្រួតពិនិត្យនិងតាមដាន | គ្រាប់ពូជបន្លែស្លែ(ត្រញ៉ាញ់ ស្ពៃខៀវ ស្ពៃឡើ ស្ពៃចង្កេះ) ត្រកួន ត្រសក់ សណ្តែកគួរនិងត្រប់) | ៦.០០០ | ៧/២០១៩ | ៦/២០២២ |
| ចិញ្ចឹមមាន់ និងទាតាមបច្ចេកទេសជាលក្ខណៈគ្រួសារ ៦០ គ្រួសារ | - ជ្រើសរើសគ្រួសារស្ម័គ្រចិត្ត<br>- បណ្តុះបណ្តាលចិញ្ចឹមមាន់តាមបច្ចេកទេស ជាលក្ខណៈគ្រួសារ<br>- ធ្វើទ្រុង និងផ្តល់ពូជចិញ្ចឹម<br>- តាមដានត្រួតពិនិត្យ | ពូជក្នុងស្រុក | ១៨.០០០ | ៧/២០១៩ | ៦/២០២២ |

| | | | | | |
|---|---|---|---|---|---|
| ចិញ្ចឹមជ្រូកតាមបច្ចេកទេសជាលក្ខណៈគ្រួសារ ៣០គ្រួសារ | - ជ្រើសរើសគ្រួសារស្ម័គ្រចិត្ត<br>- បណ្តុះបណ្តាលចិញ្ចឹមជ្រូកតាមបច្ចេកទេសជាលក្ខណៈគ្រួសារ<br>- ធ្វើទ្រុង និងផ្តល់ពូជ<br>- តាមដានត្រួតពិនិត្យ | ពូជក្នុងស្រុក | ៩.០០០ | ៧/២០១៩ | ៦/២០២២ |
| ជំនួញខ្នាតតូចជាលក្ខណៈគ្រួសារ១០គ្រួសារ | - ជ្រើសរើសគ្រួសារស្ម័គ្រចិត្ត<br>- បង្កើតគោលការណ៍<br>- ផ្តល់/បញ្ចីមុខទំនិញ<br>- ត្រួតពិនិត្យតាមដាន | បញ្ចីមុខទំនិញ | ៣.០០០ | ៧/២០១៩ | ៦/២០២២ |

### ឃ.២.២. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ត្រូវបានរៀបចំខាងក្រោម៖

| ប្រភេទវារីវប្បកម្ម | សកម្មភាព | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ (ក្បាល) | ខែ/ឆ្នាំ | |
|---|---|---|---|---|---|---|
| | | | | | ចាប់ផ្តើម | ប្រមូលផល |
| ចិញ្ចឹមត្រីអណ្តែងក្នុងអាងតាមបច្ចេកទេសជាលក្ខណៈគ្រួសារ (១០ គ្រួសារ/ឆ្នាំ) | -ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>-បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ<br>-ធ្វើអាងនិងដាក់កូនត្រីចិញ្ចឹម<br>-ត្រួតពិនិត្យតាមដាន | ១០គ្រួសារអាងទំហំ ៥ម×៤ម | ត្រីអណ្តែង | ១.០០០ | ៧/២០១៩ | ៦/២០២២ |

### ឃ.២.៣. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច

ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ត្រូវបានរៀបចំខាងក្រោម៖

| សកម្មភាព | ថវិកា (ដុល្លារ) | ចំនួន | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|
| សាងសង់លូកាត់ផ្លូវ២កន្លែង | ១.០០០ | ២ កន្លែង | ៧/២០១៩ | ៦/២០២២ |
| សាងសង់បង្គន់អនាម័យតាមគ្រួសារ | ១០.០០០ | ១០០បង្គន់ | ៧/២០១៩ | ៦/២០២២ |
| ប្រជាពលរដ្ឋមានតម្រូវការធុងចម្រះ | ៥.០០០ | ២០០ ធុង | ៧/២០១៩ | ៦/២០២២ |
| សាងសង់បង្គន់អនាម័យមួយកន្លែងនៅការិយាល័យសហគមន៍នេសាទ | ៥០០ | ១កន្លែង | ៧/២០១៩ | ៦/២០២២ |

ឃ.៣. ការគ្រប់គ្រង

ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស

ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស ត្រូវបានរៀបចំខាងក្រោម៖

| សកម្មភាព | តម្រូវការសម្ភារ | ថវិកា (ដុល្លារ) | ចំនួន | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| សហគមន៍ចុះល្បាតដោយខ្លួនឯង | | ៤.៥០០ | ៣ដង/១ខែ | ៧/២០១៩ | ៦/២០២២ |
| ចុះល្បាតដោយសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់បទល្មើសមកពីក្រៅ | | | ២ដង/១ខែ | ៧/២០១៩ | ៦/២០២២ |
| ប្រេងសម្រាប់ល្បាត | | | ៥០ លីត្រ/ខែ | ៧/២០១៩ | ៦/២០២២ |
| សេវាជួសជុលនិងថែទាំទូក និងម៉ាស៊ីន | | | ២ ដង/ឆ្នាំ | ៧/២០១៩ | ៦/២០២២ |
| ផ្តល់សម្ភារៈល្បាត (១ ឈុត) | អាវពោង | ១.០០០ | ៧ អាវ | ៧/២០១៩ | ១២/២០១៩ |
| | អាវភ្លៀង | | ៧ អាវ | | |
| | គោមបំភ្លឺពាក់ក្បាល | | ៣ គោម | | |
| | វិទ្យុទាក់ទង | | ២ គ្រឿង | | |
| | កែវយឹត | | ២ គ្រឿង | | |
| | ម៉ាស៊ីនថត | | ២ គ្រឿង | | |
| | អង្រឹង | | ៧ អង្រឹង | | |
| | តង់គ្របទូក ៤មគុណ៦ម | | ១ តង់ | | |
| | សម្ភារត្រួតពិនិត្យទឹក | | ១ កំប្លេ | | |
| | ស្លាបចក្រ | | ៦ គ្រឿង | | |
| | សោរសម្រាប់ជួសជុលទូក | | ១ សម្រាប់ | | |
| | សោរច្រវាក់ចាក់ទូក | | ២ សោរ | | |
| ទិញទូកស្ទាច់ម៉ាស៊ីន (១៨ សេះ) | | ៣.០០០ | ២ គ្រឿង | ៧/២០១៩ | ១២/២០១៩ |
| សាងសង់ទីស្នាក់ការសហគមន៍ | ដីសាធារណៈនៅភូមិបានប៉ុង | | ១ កន្លែង | ៧/២០១៩ | ១២/២០១៩ |

ឃ.៣.២. ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ

ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ ត្រូវបានរៀបចំខាងក្រោម៖

| សកម្មភាព | ថវិកា (ដុល្លារ) | ចំនួន | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|
| ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | | ១ដង/១ខែ | ៧/២០១៩ | ៦/២០២២ |
| ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | | ១ដង/១ខែ | ៧/២០១៩ | ៦/២០២២ |

| | | | | |
|---|---|---|---|---|
| បណ្តុះបណ្តាលអំពីរបៀបធ្វើកំណត់ហេតុ សរសេរលិខិតរដ្ឋបាល របាយការណ៍ និងរៀបចំទុកឯកសារ | ៥០ | ១លើក/១ឆ្នាំ | ៧/២០១៩ | ៦/២០២២ |
| បណ្តុះបណ្តាលអំពីការគ្រប់គ្រងថវិកា | ៥០ | ១លើក/១ឆ្នាំ | ៧/២០១៩ | ៦/២០២២ |
| បណ្តុះបណ្តាលអំពីការដោះស្រាយទំនាស់ | ៥០ | ១លើក/១ឆ្នាំ | ៧/២០១៩ | ៦/២០២២ |
| បណ្តុះបណ្តាលអំពីរបៀបសរសេរគម្រោងសំណើ | ៥០ | ១លើក/១ឆ្នាំ | ៧/២០១៩ | ៦/២០២២ |
| បណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ | ៥០ | ១លើក/១ឆ្នាំ | ៧/២០១៩ | ៦/២០២២ |
| បណ្តុះបណ្តាលអំពីជំនាញសម្របសម្រួល | ៥០ | ១លើក/១ឆ្នាំ | ៧/២០១៩ | ៦/២០២២ |
| បណ្តុះបណ្តាលអំពីការរៀបចំផែនការ | ៥០ | ១លើក/១ឆ្នាំ | ៧/២០១៩ | ៦/២០២២ |
| ទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ | ៤.៥០០ | ១លើក/១ឆ្នាំ | ៧/២០១៩ | ៦/២០២២ |

### ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ

ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ ត្រូវបានរៀបចំខាងក្រោម៖

| សកម្មភាព | ថវិកា (ដុល្លារ) | ចំនួន | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|
| ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃ ក្នុងសហគមន៍នេសាទ | ៩០០ | ១ដង/ឆ្នាំ | ៧/២០១៩ | ៦/២០២២ |
| ផ្សព្វផ្សាយកិច្ចព្រមព្រៀងសហគមន៍ | | ១ដង/ឆ្នាំ | ៧/២០១៩ | ៦/២០២២ |
| ផ្សព្វផ្សាយដែននេសាទសហគមន៍ | | ១ដង/ឆ្នាំ | ៧/២០១៩ | ៦/២០២២ |
| ផ្សព្វផ្សាយពីការប្រមូលប្រាក់បដិភាគ | | ១ដង/ឆ្នាំ | ៧/២០១៩ | ៦/២០២២ |
| ផ្សព្វផ្សាយច្បាប់ជលផល និងបទដ្ឋានបច្ចេកទេសពាក់ព័ន្ធ | | ១ដង/ឆ្នាំ | ៧/២០១៩ | ៦/២០២២ |
| យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងអំពីសារប្រយោជន៍ធនធានជលផល | | ១ដង/ឆ្នាំ | ៧/២០១៩ | ៦/២០២២ |
| ប្រជុំផ្សព្វផ្សាយអំពីតួនាទីរបស់បុរស ស្ត្រីក្នុងសហគមន៍នេសាទ និងការងារផ្ទះ សមភាពនិងសមធម៌យេនឌ័រ | ៦០០ | ១ដង/ឆ្នាំ | ៧/២០១៩ | ៦/២០២២ |

### ឃ.៣.៤.ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ត្រូវបានរៀបចំខាងក្រោម៖

| សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | អ្នកទទួលខុសត្រូវ | ផ្សេងៗ |
|---|---|---|---|---|
| ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅសមាជិកសហគមន៍តាមរយៈ បុណ្យទាន មហាសន្និបាតប្រចាំឆ្នាំ | ៧/២០១៩ | ៦/២០២២ | គណៈកម្មការសហគមន៍នេសាទ | |
| បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងកម្មវិធីវិនិយោគឃុំ | ៧/២០១៩ | ៦/២០២២ | គណៈកម្មការសហគមន៍នេសាទ | |

### ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ត្រូវបានរៀបចំខាងក្រោម៖

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ | ចំណូលសរុប (ដុល្លារ) | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានសមាជិកភាព | ចុះប្រមូលប្រាក់សមាជិកភាព | ៧/២០១៩ | ៦/២០២២ | | |
| ភាគទានប្រចាំឆ្នាំពីសមាជិក | ចុះប្រមូលប្រាក់ភាគទានប្រចាំឆ្នាំ | ៧/២០១៩ | ៦/២០២២ | ១៦៨ | |
| ភាគទានពីអ្នកខាងក្រៅ និងអ្នកមិនមែនជាសមាជិកសហគមន៍នេសាទ | ប្រមូលប្រាក់ភាគទានពីអ្នកនេសាទខាងក្រៅ | ៧/២០១៩ | ៦/២០២២ | ១៤.៥៨០ | |
| | ប្រមូលប្រាក់អ្នកមិនមែនជាសមាជិកសហគមន៍នេសាទ | ៧/២០១៩ | ៦/២០២២ | ២.៧០០ | |
| ប្រាក់ចំណូលពីប្រភពផ្សេងៗ (ជំនួយពីរាជរដ្ឋាភិបាល ជំនួយពីអង្គការជាតិ និងអង្គការមិនមែន រដ្ឋាភិបាល និងអំណោយពីសប្បុរសជន) | • បញ្ចូលផែនការអភិវឌ្ឍសហគមន៍ ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ<br>• ទំនាក់ទំនងជាមួយស្ថាប័នជលផល<br>• សរសេរគម្រោងស្នើសុំពីអង្គការដៃគូ | ៧/២០១៩ | ៦/២០២២ | ៦៩.៤២២ | |

### ង. ផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ត្រូវបានរៀបចំខាងក្រោម៖

| សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ | អ្នកទទួលខុសត្រូវ |
|---|---|---|---|
| ប្រជុំផ្ទៃក្នុងប្រចាំត្រីមាសគណៈកម្មការសហគមន៍នេសាទ | ៧/២០១៩ | ៦/២០២២ | -គណៈកម្មការសហគមន៍ នេសាទ<br>-អាជ្ញាធរឃុំ |
| រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំ ដោយមានការចូលរួមពីស្ត្រី | ៧/២០១៩ | ៦/២០២២ | |

### ច. យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោម ៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការ រួមមានសមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ សមាជិកសហគមន៍នេសាទ ដែលមានបទពិសោធន៍ និងចំណេះដឹងល្អ ជាពិសេសអំពីបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់លើផែនការណា ដែលទាក់ទងនឹងបច្ចេកទេសជលផលដូចជា ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី និងការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការដៃគូគម្រោង និងម្ចាស់ជំនួយ ដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗឱ្យបានជាក់លាក់

- ទាក់ទងជាមួយរដ្ឋបាលជលផល ដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជំរុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀរគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ
- ជ្រើសរើសស្ត្រីមេគ្រួសារ ជាសមាជិកចំនួនយ៉ាងតិច៧% ចូលរួមក្នុងសកម្មភាពទ្រទ្រង់ជីវភាពរស់នៅ
- អញ្ជើញស្ត្រីជាសមាជិកសហគមន៍នេសាទចូលរួមយ៉ាងតិច ៤០% ក្នុងការបណ្តុះបណ្តាល សិក្ខាសាលានិងសកម្មភាព ទ្រទ្រង់ជីវភាពរស់នៅ និងវារីវប្បកម្ម
- កម្មករគ្មានជំនាញជាស្ត្រីជាសមាជិកសហគមន៍នេសាទ៤០%ចូលរួមសកម្មភាពហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច
- អញ្ជើញស្ត្រីមេគ្រួសារជាសមាជិកសហគមន៍នេសាទ ចូលរួមប្រជុំ និងចូលរួមសកម្មភាព និងចូលជាគណៈកម្មការរបស់សហគមន៍
- ជ្រើសរើសស្ត្រីជាសមាជិកសហគមន៍នេសាទ ៥០% ចូលរួមក្នុងសកម្មភាពគាំទ្រជីវភាព
- ផ្តល់ឱកាសស្ត្រី៥០%ជាសមាជិកសហគមន៍នេសាទចូលរួមក្នុងសកម្មភាពគាំទ្រជីវភាព និងទទួលផលប្រយោជន៍ពីគម្រោងក្នុងនោះស្ត្រីជាមេគ្រួសារ ៧%
- លើកទឹកចិត្តស្ត្រីជាគណៈកម្មាការចូលរួមក្នុងការសម្រេចចិត្តនានា
- លើកទឹកចិត្តស្ត្រីជាគណៈកម្មាការមិនបោះបង់ចោលការងារ
- រៀបចំការប្រជុំឱ្យសមស្របនឹងពេលវេលារបស់ស្ត្រី ដែលមានលទ្ធភាពចូលរួម
- ជំរុញឱ្យមានស្ត្រីយ៉ាងតិច ២៥% ជាសមាជិកគណកម្មាការសហគមន៍នេសាទ។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍រយៈពេល ៣ ឆ្នាំ (កក្កដា ២០១៩ - មិថុនា ២០២២)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្ដើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| **ឃ.១. ធនធានជលផល និងអេកូឡូស៊ី** | | | | | | | |
| ឃ.១.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ | ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទដែលអនុញ្ញាត ទំហំ ពេលវេលា និងទីកន្លែងនេសាទនិងប្រភេទឧបករណ៍នេសាទហាមឃាត់ | ផែនការប្រើប្រាស់ឧបករណ៍នេសាទត្រូវបានផ្សព្វផ្សាយ ២ ដង ក្នុង០១ឆ្នាំ (រដូវបិទ និងបើកនេសាទ) | ១២០ | អង្គការដៃគូ រដ្ឋបាលជលផល សហគមន៍ | ៧/២០១៩ | ៦/២០២២ | |
| ឃ.១.២. ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ | បោះបង្គោលព្រំធ្វើពីស៊ីម៉ង់ចំនួន ១០ បង្គោល | មានបង្គោលព្រំ ១០ បង្គោល | ៤.០០០ | អង្គការដៃគូ រដ្ឋបាលជលផល អាជ្ញាធរឃុំ | ៧/២០១៩ | ៦/២០២២ | |
| | តម្លើងផ្ទាំងប៉ាណូផែនទីសហគមន៍ នេសាទចំនួន ២ផ្ទាំង | មានផ្ទាំងប៉ាណូ ២ផ្ទាំង | ១.០០០ | | ៧/២០១៩ | ៦/២០២២ | |
| ឃ.១.៣. ផែនការគ្រប់គ្រងព្រៃលិចទឹក | ដាំព្រៃលិចទឹកតាមមាត់អូរ | ព្រៃលិចទឹកត្រូវបានដាំឡើងវិញនៅតាមអូរចំនួន ០៤ | ៣០០ | អង្គការដៃគូ រដ្ឋបាលជលផល អាជ្ញាធរឃុំ | ៧/២០១៩ | ៦/២០២២ | |
| | ដាក់ស្លាកសញ្ញាហាមកាប់ព្រៃលិចទឹក ចំនួន ២០ស្លាកតូចៗ | មាន២០ ស្លាកសញ្ញាតូចៗ | ៣០០ | | | | |
| **ឃ.២. គាំទ្រជីវភាពប្រជាពលរដ្ឋ** | | | | | | | |
| ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល | ចិញ្ចឹមមាន់ និងទាតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | មានគ្រួសារចិញ្ចឹមមាន់៦០គ្រួសារ | ១៨.០០០ | អង្គការដៃគូ រដ្ឋបាលជលផល | ៧/២០១៩ | ៦/២០២២ | |
| | ចិញ្ចឹមជ្រូកតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | មានគ្រួសារចិញ្ចឹមជ្រូក៣០គ្រួសារ | ៩.០០០ (៣០x៣០០) | | ៧/២០១៩ | ៦/២០២២ | |
| | រៀបចំសួនបន្លែតាមគ្រួសារ | មានគ្រួសារដាំបន្លែ២០ គ្រួសារ | ៦.០០០ | | ៧/២០១៩ | ៦/២០២២ | |
| | ជំនួញខ្នាតតូចលក្ខណៈគ្រួសារ | មានគ្រួសារធ្វើជំនួញខ្នាតតូច | ៣.០០០ | | ៧/២០១៩ | ៦/២០២២ | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | ១០ គ្រួសារ | | | | | |
| ឃ.២.២. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | ចិញ្ចឹមត្រីអណ្តែងក្នុងអាង ឬស្រះតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | មានគ្រួសារចិញ្ចឹមត្រីអណ្តែងក្នុងអាងឬស្រះ១០ គ្រួសារ | ៣.០០០ | អង្គការដៃគូ រដ្ឋបាលជលផល | ៧/២០១៩ | ៦/២០២២ | |
| ឃ.២.៣. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធ | សាងសង់លូកាត់ផ្លូវពីកន្លែង | មានលូកាត់ផ្លូវ ២កន្លែង | ១.០០០ | អង្គការដៃគូ រដ្ឋបាលជលផល | ៧/២០១៩ | ៦/២០២២ | |
| | សាងសង់បង្គន់ប្រជាពលរដ្ឋ | មានបង្គន់ ១០០កន្លែង | ១០.០០០ | | ៧/២០១៩ | ៦/២០២២ | |
| | ផ្តល់ធុងចម្រោះទឹក | មានធុងចម្រោះទឹក ២០០ ធុង | ៥.០០០ | | ៧/២០១៩ | ៦/២០២២ | |
| | បង្គន់នៅការិយាល័យនេសាទ | មានបង្គន់នៅការិយាល័យ១កន្លែង | ៥០០ | | ៧/២០១៩ | ៦/២០២២ | |
| ឃ.៣. ការងារគ្រប់គ្រង | | | | | | | |
| ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស | សហគមន៍ចុះល្បាតដោយខ្លួនឯង | បានចុះល្បាត ៣ដង/ខែ | ៤.៥០០ | អង្គការដៃគូ រដ្ឋបាលជលផល អាជ្ញាធរឃុំ | ៧/២០១៩ | ៦/២០២២ | |
| | ចុះល្បាតដោយសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់បទល្មើសមកពីក្រៅ | បានចុះល្បាត២ដង/១ខែ សហការជាមួយអាជ្ញាធរមុលដ្ឋាន | | | ៧/២០១៩ | ៦/២០២២ | |
| | ប្រេងសម្រាប់ល្បាត | មានប្រេង ៥០លីត្រ/១ខែ | | | | | |
| | សេវាជួសជុល ថែទាំទូក និងម៉ាស៊ីន | បានជួសជុលទូក និងម៉ាស៊ីន ២ដង/ឆ្នាំ | | | | | |
| | ផ្តល់សម្ភារល្បាត | មានសម្ភារល្បាត ១ឈុត | ១.០០០ | | ៧/២០១៩ | ៦/២០២២ | |
| | ទិញទូកស្ពាច់ម៉ាស៊ីន | មានទូកម៉ាស៊ីនចំនួន ២គ្រឿង (១តូច ១ធំ) | ៣.០០០ | | ៧/២០១៩ | ៦/២០២២ | |
| | សាងសង់ទីស្នាក់ការសហគមន៍ | មានស្នាក់ការ១ខ្នងសម្រាប់សហគមន៍នេសាទធ្វើការងារ | ៣.០០០ | | ៧/២០១៩ | ៦/២០២២ | |
| ឃ.៣.២. ផែនការពង្រឹងគណៈកម្មការ | ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | បានប្រជុំ ១ដង/១ខែ | មិនត្រូវការថវិកា | អង្គការដៃគូ រដ្ឋបាលជលផល | ៧/២០១៩ | ៦/២០២២ | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| សហគមន៍នេសាទ | ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | បានប្រជុំ១ដង/១ខែជាមួយក្រុមប្រឹក្សាឃុំ | មិនត្រូវការថវិកា | អាជ្ញាធរឃុំ | ៧/២០១៩ | ៦/២០២២ | |
| | បណ្តុះបណ្តាលអំពីរបៀបធ្វើកំណត់ហេតុ សរសេរលិខិតរដ្ឋបាល របាយការណ៍ និងរៀបចំទុកឯកសារ | -មានវគ្គបណ្តុះបណ្តាលលើមុខជំនាញនិមួយៗ ១លើក/១ឆ្នាំ<br>-សមត្ថភាពសហគមន៍នេសាទបានប្រសើឡើង<br>-គណៈកម្មការសហគមន៍នេសាទអាចអនុវត្តន៍បាន | ៥០ | | ៧/២០១៩ | ៦/២០២២ | |
| | បណ្តុះបណ្តាលការគ្រប់គ្រងថវិកា | | ៥០ | | ៧/២០១៩ | ៦/២០២២ | |
| | បណ្តុះបណ្តាលការដោះស្រាយទំនាស់ | | ៥០ | | ៧/២០១៩ | ៦/២០២២ | |
| | បណ្តុះបណ្តាលអំពីរបៀបសរសេរគម្រោងសំណើ | | ៥០ | | ៧/២០១៩ | ៦/២០២២ | |
| | បណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ | | ៥០ | | ៧/២០១៩ | ៦/២០២២ | |
| | បណ្តុះបណ្តាលជំនាញសម្របសម្រួល | | ៥០ | | ៧/២០១៩ | ៦/២០២២ | |
| | បណ្តុះបណ្តាលអំពីការរៀបចំផែនការសកម្មភាពការងារ | | ៥០ | | ៧/២០១៩ | ៦/២០២២ | |
| | ទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ | -បានទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍១លើក/ឆ្នាំ<br>-បានទទួលនូវបទពិសោធន៍ល្អ | ៤.៥០០ | | ៧/២០១៩ | ៦/២០២២ | |
| ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ | ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃ ក្នុងសហគមន៍នេសាទ | បានផ្សព្វផ្សាយ ១ដង/ឆ្នាំ | ៩០០ | អង្គការដៃគូ រដ្ឋបាលជលផល | ៧/២០១៩ | ៦/២០២២ | |
| | ផ្សព្វផ្សាយកិច្ចព្រមព្រៀងសហគមន៍ | បានផ្សព្វផ្សាយ ១ដង/ឆ្នាំ | ១៥០ | | ៧/២០១៩ | ៦/២០២២ | |
| | ផ្សព្វផ្សាយដែននេសាទនិងកន្លែងអភិរក្សរបស់សហគមន៍ | បានផ្សព្វផ្សាយ ១ដង/ឆ្នាំ | ១៥០ | | ៧/២០១៩ | ៦/២០២២ | |
| | ផ្សព្វផ្សាយការប្រមូលប្រាក់បដិភាគ | បានផ្សព្វផ្សាយ ១ដង/ឆ្នាំ | ១៥០ | | ៧/២០១៩ | ៦/២០២២ | |



th

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | ផ្សព្វផ្សាយច្បាប់ជលផល និងបទដ្ឋានបច្ចេកទេសពាក់ព័ន្ធ | បានផ្សព្វផ្សាយ ១ដង/ឆ្នាំ | ១៥០ | | ៧/២០១៩ | ៦/២០២២ | |
| | យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងអំពីសារប្រយោជន៍ធនធានជលផល | បានផ្សព្វផ្សាយ ១ដង/ឆ្នាំ | ១៥០ | | ៧/២០១៩ | ៦/២០២២ | |
| | ប្រជុំផ្សព្វផ្សាយអំពីតួនាទីរបស់បុរស ស្ត្រីក្នុងសហគមន៍នេសាទ សមភាព និងសមធម៌យេនឌ័រ | បានផ្សព្វផ្សាយ ១ដង/ឆ្នាំ | ៦០០ | | ៧/២០១៩ | ៦/២០២២ | |
| យ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅសមាជិកសហគមន៍តាមរយៈបុណ្យទានមហាសន្និបាតប្រចាំឆ្នាំ | បានផ្សព្វផ្សាយ ១ដង/ឆ្នាំ | ៣០០ | អង្គការដៃគូ រដ្ឋបាលជលផល | ៧/២០១៩ | ៦/២០២២ | |
| | បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងកម្មវិធីវិនិយោគឃុំ | បានផ្សព្វផ្សាយ ១ដង/ឆ្នាំ | | អង្គការដៃគូ រដ្ឋបាលជលផល | ៧/២០១៩ | ៦/២០២២ | |
| យ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | ភាគទានសមាជិកភាព | សមាជិកសហគមន៍បានបង់ភាគទានសមាជិកភាព | | សហគមន៍នេសាទ | ៧/២០១៩ | ៦/២០២២ | |
| | ភាគទានប្រចាំឆ្នាំ | សមាជិកសហគមន៍បានបង់ភាគទានប្រចាំឆ្នាំ ១ឆ្នាំម្តង | ១៦៨ | | ៧/២០១៩ | ៦/២០២២ | |
| | ភាគទានពីអ្នកខាងក្រៅ និងអ្នកមិនមែនជាសមាជិកសហគមន៍នេសាទ | បានទទួលប្រាក់បដិភាគពីអ្នកនេសាទមកពីខាងក្រៅ | ១៤.៥៨០ | | ៧/២០១៩ | ៦/២០២២ | |
| | | បានទទួលប្រាក់បដិភាគពីអ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទ | ២.៧០០ | | ៧/២០១៩ | ៦/២០២២ | |
| | ប្រាក់ចំណូលពីប្រភពផ្សេងៗ(ជំនួយ | សហគមន៍នេសាទទទួល | ៦៩.៤២២ | អង្គការដៃគូ | ៧/២០១៩ | ៦/២០២២ | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | ពីរាជរដ្ឋាភិបាល ជំនួយពីអង្គការជាតិ និងអង្គការមិនមែនរដ្ឋាភិបាល និងអំណោយសប្បុរសជន) | បានកញ្ចប់ថវិកាពីប្រភពស្របច្បាប់ផ្សេងៗ | | រដ្ឋបាលជលផល អាជ្ញាធរឃុំ | | | |
| ង. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ | ប្រជុំផ្ទៃក្នុង ប្រចាំត្រីមាសរបស់គណៈកម្មការសហគមន៍នេសាទ | ៤ត្រីមាស/ឆ្នាំ | | អង្គការដៃគូ រដ្ឋបាលជលផល | ៧/២០១៩ | ៦/២០២២ | |
| | រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំ ដោយមានការចូលរួមពីស្ត្រី | ១ដង/ឆ្នាំ | ៦០០ | អង្គការដៃគូ រដ្ឋបាលជលផល អាជ្ញាធរមូលដ្ឋាន | ៧/២០១៩ | ៦/២០២២ | |

សម្គាល់ ៖ សហគមន៍នេសាទនៅខេត្តក្រចេះនិងស្ទឹងត្រែងដែលគម្រោងគាំទ្របានចាប់ផ្តើមរៀបចំផែនការគ្រប់គ្រង នៅត្រីមាសទី៤ ឆ្នាំ២០១៨។



th

# តារាងកម្មវិធីការងារប្រចាំឆ្នាំ (ខែកក្កដា ២០១៩ -មិថុនា ២០២២)

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| **ឃ.១. ធនធានជលផល និងអេកូឡូស៊ី** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ឃ.១.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទដែលអនុញ្ញាត ទំហំ ពេលវេលា និងទីកន្លែងនេសាទ និងប្រភេទឧបករណ៍នេសាទហាមឃាត់ | | | | x | | | | | | | x | | | | | x | | | | | | | x | | | | | x | | | | | | | x | |
| ឃ.១.២. ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| បោះបង្គោលព្រំធ្វើពីស៊ីម៉ង់ ចំនួន០៨ បង្គោល | | | | | | | x | x | | | | | | | | | | | | | | | | | | | | | | | | | | | | |
| តម្លើងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ ចំនួន៣ផ្ទាំង | | | | | | x | x | x | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ឃ.១.៣. ផែនការគ្រប់គ្រងព្រៃលិចទឹក | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ដាំព្រៃលិចទឹកតាមមាត់អូរ ៣ | | | | | | | | | | x | x | x | | | | | | | | | | x | x | x | | | | | | | | | | x | x | x |
| ដាក់ស្លាកសញ្ញាហាមកាប់ព្រៃលិចទឹក ចំនួន២០ផ្ទាំង | | | | | | | | | | | | | x | x | x | | | | | | | | | | | | | | | | | | | | | |
| **ឃ.២. គាំទ្រជីវភាពប្រជាពលរដ្ឋ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ធ្វើស្រូវ... និងទាតាមបច្ចេកទេសបាលីគ្នាៈគ្រួសារ | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០១០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| ចិញ្ចឹមជ្រូកតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| រៀបចំសួនបន្លែតាមគ្រួសារ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ជំនួញខ្នាតតូចលក្ខណៈគ្រួសារ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ឃ.២.២. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចិញ្ចឹមត្រី អណ្តែងក្នុងស្រះតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ឃ.២.៣. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| សាងសង់លូកាត់ផ្លូវ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| សាងសង់ការិយាល័យនេសាទ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| សាងសង់បង្គន់ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ផ្តល់ធុងចម្រោះទឹក | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ឃ.៣. ការងារគ្រប់គ្រង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| សហគមន៍ចុះល្បាតខ្លួនឯង | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ចុះល្បាតដោយសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់បទល្មើសមកពីក្រៅ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ផ្តល់សម្ភារល្បាត | X | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ទិញទូកស្ទាច់ម៉ាស៊ីន | X | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ប្រេងសម្រាប់ល្បាត | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| សេវាជួសជុល ថែទាំទូកម៉ាស៊ីន | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០១០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| ឃ.៣.២. ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| បណ្ដុះបណ្ដាលអំពីរបៀបធ្វើកំណត់ហេតុ សរសេរលិខិតរដ្ឋបាលរបាយការណ៍ និងរៀបចំទុកឯកសារ | | | | | | | | | | | | x | | | | | | | | | | | x | | | | | | | | | | | | x | |
| បណ្ដុះបណ្ដាលការគ្រប់គ្រងថវិកា | | | | | | | | | | | x | | | | | | | | | | | x | | | | | | | | | | | | x | | |
| បណ្ដុះបណ្ដាលអំពីការដោះស្រាយទំនាស់ | | | | | | | | | | x | | | | | | | | | | | x | | | | | | | | | | | | x | | | |
| បណ្ដុះបណ្ដាលអំពីរបៀបសរសេរគម្រោងសំណើ | | | | | | | | | x | | | | | | | | | | | x | | | | | | | | | | | | x | | | | |
| បណ្ដុះបណ្ដាលភាពជាអ្នកដឹកនាំ | | | | | | | x | | | | | | | | | | | | x | | | | | | | | | | | | x | | | | | |
| បណ្ដុះបណ្ដាលអំពីការរៀបចំផែនការ | | | | | | | x | | | | | | | | | | | | x | | | | | | | | | | | | x | | | | | |
| ទស្សនកិច្ចសិក្សាផ្លាស់ប្ដូរបទពិសោធន៍ | | | | | | x | | | | | | | | | | | | x | | | | | | | | | | | | x | | | | | | |
| ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយព្រឹត្តិប័ត្រ: និងបទ[illegible]ក្នុងសហគមន៍នេសាទ | | | | x | | | | | x | | | | | | | x | | | | | x | | | | | | | x | | | | | x | | | |



ឋ

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| ផ្សព្វផ្សាយកិច្ចព្រមព្រៀងស.ន | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | |
| ផ្សព្វផ្សាយដែននេសាទនិងកន្លែងអភិរក្សរបស់សហគមន៍ | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | |
| ផ្សព្វផ្សាយការប្រមូលប្រាក់បដិភាគ | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | |
| ផ្សព្វផ្សាយច្បាប់ជលផល និងបទដ្ឋានបច្ចេកទេសពាក់ព័ន្ធ | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | |
| យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងអំពីសារប្រយោជន៍ធនធានជលផល | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | |
| ប្រជុំផ្សព្វផ្សាយអំពីតួនាទីរបស់បុរស ស្ត្រីក្នុងសហគមន៍នេសាទ | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | |
| ឃ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅសមាជិកសហគមន៍តាមរយៈបុណ្យទានមហាសន្និបាតប្រចាំឆ្នាំ | | X | | | | | | | | | | | | X | | | | | | | | | | | | | X | | | | | | | | | |
| បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងកម្មវិធីវិនិយោគឃុំ | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | |
| ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ភាគទានសមាជិកភាព | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |



ឥ

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០១០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| ភាគទានប្រចាំឆ្នាំ | | | | | | | x | | | | | | | | | | | | x | | | | | | | | | | | | x | | | | | |
| ប្រាក់បដិភាគអ្នកនេសាទក្រៅ | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| ប្រាក់បដិភាគមិនមែនជាសមាជិកសហគមន៍នេសាទ | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| ប្រាក់ចំណូលពីប្រភពផ្សេងៗ (អំណោយពីរាជរដ្ឋាភិបាល អំណោយពីសប្បុរសជន ជំនួយពីអង្គការជាតិ និងអង្គការមិនមែនរដ្ឋាភិបាល) | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| ង. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ប្រជុំផ្ទៃក្នុង ប្រចាំត្រីមាសរបស់គណៈកម្មការសហគមន៍នេសាទ | | | x | | | x | | | x | | | x | | | x | | | x | | | x | | | x | | | x | | | x | | | x | | | x |
| រៀបចំមហាសន្និបាតសហគមន៍នេសាទប្រចាំឆ្នាំ ដោយមានការចូលរួមពីស្ត្រី | | | | | | x | | | | | | | | | | | | x | | | | | | | | | | | | x | | | | | | |

លេខ : ០១០/១៩

បានឃើញ និងបញ្ជូនមក

លោកនាយខណ្ឌរដ្ឋបាលជលផលស្ទឹងត្រែង

" ដើម្បីជូនពិនិត្យ និងសម្រួល"

ថ្ងៃ..............ខែ..........ឆ្នាំ..........ព.ស ២៥៦៣

សេកុង ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ២០១៩

នាយផ្នែករដ្ឋបាលជលផលសេកុង

លោក ...

លេខ : ២៥០/១៩

បានឃើញ និងបញ្ជូនមក

លោកនាយផ្នែករដ្ឋបាលជលផលសេកុង

" ដើម្បីជូនពិនិត្យ និងសម្រួល"

ថ្ងៃ..............ខែ..........ឆ្នាំ..........ព.ស ២៥៦៣

ឃុំភ្លុក ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ២០១៩

មេឃុំភ្លុក

ឌួន ចាំង

សូមគោរពជូន

លោកមេឃុំភ្លុក

" ដើម្បីជូនពិនិត្យ និងសម្រួល"

ថ្ងៃ..............ខែ..........ឆ្នាំ..........ព.ស ២៥៦៣

ភូមិភ្លុក ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ២០១៩

ប្រធានគណៈកម្មការសហគមន៍នេសាទ

ភ្លុកមានជ័យ

លេខ : ០៤២/១៩ ខ.ជ.ស.ត

បានឃើញ និងគោរពជូន

លោកប្រធាន

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្ទឹងត្រែង

" ដើម្បីជូនពិនិត្យ និងសម្រួល"

ថ្ងៃ..............ខែ..........ឆ្នាំ..........ព.ស២៥៦៣

ស្ទឹងត្រែង ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ២០១៩

នាយខណ្ឌរដ្ឋបាលជលផលស្ទឹងត្រែង

ទុំ នីរ៉ូ

លេខ : ៦៧៦ កសក

បានឃើញ និងគោរពជូន

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

" ដើម្បីជូនពិនិត្យ និងសម្រេចដោយអនុគ្រោះ"

ថ្ងៃ..............ខែ..........ឆ្នាំ..........ព.ស២៥៦៣

ស្ទឹងត្រែង ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ២០១៩

ប្រធាន

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្ទឹងត្រែង

លៀង_សេង

លេខ : ២៤២០

បានឃើញ និងឯកភាព

ថ្ងៃ..............ខែ..........ឆ្នាំ..........ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០១៩

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

**អេង ជាសាន**